ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
№ ៥២៤ ឧរថ.អរ.ធរ.

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០០៨

# អាជ្ញាប័ណ្ណស្វែងរករ៉ែ

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៥ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការគ្រប់គ្រង និង ការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញកិច្ចព្រមព្រៀងស្ដីពីការសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មរ៉ែលោហៈនៅតំបន់ស្រុកបានលុង ស្រុកលំផាត់ និងស្រុកកូនមុំ ខេត្តរតនគីរី រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមហ៊ុន LIBERTY MINING INTERNATIONAL PTY LTD ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៨។

## សម្រេច

**ប្រការ១:** អនុញ្ញាតអោយក្រុមហ៊ុន LIBERTY MINING INTERNATIONAL PTY LTD មានអាសយដ្ឋាននៅផ្ទះលេខ #193 BEo ផ្លូវ៦៣ សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ធ្វើការសិក្សាស្រាវជ្រាវរ៉ែលោហៈនៅតំបន់ស្រុកបានលុង ស្រុកលំផាត់ និងស្រុកកូនមុំ ខេត្តរតនគីរី លើផ្ទៃដីទំហំ ៣២៨ (បីរយម្ភៃប្រាំបី) គីឡូម៉ែត្រក្រឡា ដែលមានកូអរដោណេដូចតទៅ :

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ១៤១ ទូរសារ: (៨៥៥)២៣ ៤២៨ ២៦៣
45 Preah Norodom Boulivard, Khan Daun Penh. Phone: (855) 23 211 141 Fax: (855) 23 428 263

| ចំណុច | អាប់ស៊ីស | អ័រដោនេ | ចំណុច | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| A | 6 88 000 | 15 16 000 | G | 7 22 000 | 15 06 000 |
| B | 7 02 000 | 15 16 000 | H | 7 02 000 | 15 06 000 |
| C | 7 02 000 | 15 13 000 | I | 7 02 000 | 14 94 000 |
| D | 7 16 000 | 15 13 000 | J | 6 94 000 | 14 94 000 |
| E | 7 16 000 | 15 10 000 | K | 6 94 000 | 15 11 000 |
| F | 7 22 000 | 15 10 000 | L | 6 88 000 | 15 11 000 |

**ប្រការ២:** ក្រុមហ៊ុន LIBERTY MINING INTERNATIONAL PTY LTD ត្រូវដំណើរការសិក្សាស្រាវជ្រាវរ៉ែលើផ្ទៃដីដែលបានកំណត់ខាងលើ ដោយអនុវត្តទៅតាមផែនការឆ្នាំ និងកម្មវិធីការងាររបស់ខ្លួនដោយធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសក្នុងការសិក្សាស្រាវជ្រាវរុករករ៉ែ ។

**ប្រការ៣:** អាជ្ញាប័ណ្ណនេះមានតំលៃរយៈពេល ០២ (ពីរ) ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា ។ មុនផុតកំណត់៣០ថ្ងៃ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំអនុញ្ញាតធ្វើការសិក្សាស្រាវជ្រាវរ៉ែបន្តជាថ្មី ។

**ប្រការ៤:** ក្នុងករណីប្រព្រឹត្តល្មើសលើល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៨ អាជ្ញាប័ណ្ណនេះនឹងត្រូវដកហូត ឬត្រូវពិន័យទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

**ប្រការ៥:** អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង និងប្រធានក្រុមហ៊ុន LIBERTY MINING INTERNATIONAL PTY LTD ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ៦:** អាជ្ញាប័ណ្ណនេះមានអនុភាពគតិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ

ស៊ុយ សែម

**កន្លែងទទួល**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-សាលាខេត្តរតនគិរី
-សាលាស្រុកបានលុង
-សាលាស្រុកលំផាត់
-សាលាស្រុកកូនមុំ
-ដូចប្រការ៥ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ